ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី

# សកម្មភាព និងលទ្ធផល
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆ្នាំ២០២៥

## របស់
## មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## រាជធានីភ្នំពេញ

# របាយការណ៍
# សកម្មភាព និងលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆ្នាំ២០២៥
# របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ

## ១. សភាពការណ៍រួម

មន្ត្រីរាជការកំពុងបម្រើការងារនៅក្នុងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ មានចំនួនសរុប ១៥៥នាក់ (ស្រី៣០នាក់) និងមន្ត្រីជាប់កិច្ចសន្យាសរុបចំនួន០៨នាក់(ស្រី០២នាក់)។

ការបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០២៤-២០២៥ អនុវត្តបាន ៣៤០ហ.ត=១២១,៤៣% នៃផែនការប្រចាំឆ្នាំ ២៨០ហ.ត។ ផ្ទៃដីប្រមូលផល ៣៤០ហ.ត បរិមាណផលសរុប ១២១៧តោន គិតជាទិន្នផល ៣,៥៨តោន/ហ.ត។ ដោយឡែកដំណាំសាកវប្បកម្មអនុវត្តបានចំនួន ១១០ហ.ត និងដំណាំឧស្សាហកម្មអនុវត្តបានចំនួន ៣០ហ.ត។

ការបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០២៥ អនុវត្តបាន ៤ ៣២០ហ.ត=១០២,៨៥% នៃផែនការ ៤ ២០០ហ.ត ផ្ទៃដីប្រមូលផលសរុប ៤៣២០ហ.ត បរិមាណផលសរុប ១២ ៦៦០តោន គិតជាទិន្នផល ២,៩៣តោន/ហ.ត ។ ដំណាំសាកវប្បកម្មអនុវត្តបានចំនួន ១១៥ហ.ត ដំណាំឧស្សាហកម្មអនុវត្តបានចំនួន ៤០ហ.ត ។

នៅក្នុងខែមករា មានការរាំងស្ងួតបានបង្កផលប៉ះពាល់ដល់ដំណាំស្រូវរដូវប្រាំងសរុបចំនួន២១,៥០ហ.ត នៅសង្កាត់បឹងធំ ខណ្ឌកំបូល(ភូមិក្រោក ៨ហ.ត ភូមិដូនកុក ៣.៥ហ.ត និងភូមិខ្ចៅ ១០ហ.ត) តែមិនមានការខូចខាតទេ ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ បានសហការជាមួយមន្ទីរធនធានទឹករាជធានីភ្នំពេញ និងអាជ្ញាធរភូមិ-សង្កាត់នៅមូលដ្ឋានជួយអន្តរាគមន៍បូមទឹកជួយសង្គ្រោះទាន់ពេលវេលា។

នៅដើមខែសីហា មានការរាំងស្ងួត ដែលបណ្តាលមានការប៉ះពាល់ផ្ទៃដីស្រូវសន្ទូង និងពង្រោះសរុបចំនួន ២៩៤ ហ.ត នៅក្នុងសង្កាត់ប្រទះឡាង ខណ្ឌកំបូល រាជធានីភ្នំពេញ តែមិនមានការខូចខាតទេ ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ សហការជាមួយមន្ទីរធនធានទឹក និងអាជ្ញាធរភូមិ-សង្កាត់នៅមូលដ្ឋាន អន្តរាគមន៍បូមទឹកសង្គ្រោះទាន់ពេលវេលា។

ការបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០២៥-២០២៦ ចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ២០២៥ គិតត្រឹមសប្តាហ៍ទី២ ខែធ្នូ ឆ្នាំ២០២៥ ផ្ទៃដីភ្ជួររាស់ និងដាំដុះអនុវត្តបានចំនួន ២៩៤ហ.ត = ៩៤,៨៣% នៃផែនការ ៣១០ហ.ត ដោយឡែកដំណាំសាកវប្បកម្មអនុវត្តបានចំនួន ៥២ហ.ត និងដំណាំឧស្សាហកម្មអនុវត្តបានចំនួន ១៧ហ.ត ។

នៅខែវិច្ឆិកា មានជំនន់ទឹកភ្លៀងបណ្តាលឱ្យប៉ះពាល់ដល់ផ្ទៃដីស្រូវរដូវប្រាំង នៅក្នុងសង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញសរុបចំនួន៨ហិកតា ក្នុងនោះផ្ទៃដីស្រូវចំនួន៦,៥ហិកតាបានលូតលាស់ល្អឡើងវិញ ចំណែកផ្ទៃដីស្រូវចំនួន ១,៥ហិកតាទៀតខូចខាតទាំងស្រុង និងបានព្រោះដាំស្តារឡើងវិញរួចរាល់។

ជំងឺឆ្លងសត្វដូចជា ជំងឺផ្តាសាយបក្សី និងជំងឺឆ្លងលើសត្វគោ ជ្រូក មិនត្រូវបានរកឃើញនៅក្នុងរាជធានីភ្នំពេញទេ ដោយសារមន្ត្រីបសុព្យាបាលបានចុះពិនិត្យសុខភាពសត្វ និងអនុវត្តវិធានបសុពេទ្យជាប្រចាំនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីតាំងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ សត្តឃាតដ្ឋាន និងនៅតាមទីផ្សារ ទីសាធារណៈ កន្លែងកែច្នៃផលិតផលសត្វ និងបានចុះបាញ់ថ្នាំសម្លាប់មេរោគបានសរុបចំនួន ១៨៧៨លើក។

វិស័យជលផល ផលត្រីចាប់បានសរុបចំនួន ១ ៧៥៦តោន វារីវប្បកម្មបានផលសរុប ២១ ៥០០តោន ចិញ្ចឹមកង្កែបបាន ៤,២តោន និងចិញ្ចឹមក្រពើបាន ២០០ក្បាល។ ការកែច្នៃផលនេសាទបាន ២ ៩៩០តោន និងផលិតទឹកត្រីបានសរុប ៤ ២១៧ ១៤១លីត្រ។ ការចេញលិខិតអនុញ្ញាតឱ្យបង្កើតទីតាំងទិញ លក់សន្និធិ ឬកន្លែងកែច្នៃផល ផលិតផលជលផលសរុបចំនួន១១៨ច្បាប់។ ការងារបង្ក្រាបបទល្មើសនេសាទ បានឃាត់ចាប់និងធ្វើកំណត់ហេតុបំផ្លាញចោលបានចំនួន ២៨ករណី ។

វិស័យព្រៃឈើ បណ្ដុះកូនឈើបានចំនួន ៧ ០០០ដើម បានចែកចាយកូនឈើចំនួន ៣ ៣៣៧ដើម ជូនប្រជាពលរដ្ឋ វត្តអារាម និងស្ថាប័ននានា បានដាំកូនឈើចំនួន ៣៨៦ដើម។ ការចេញលិខិតអនុញ្ញាតឲ្យបង្កើត និងបន្តសុពលភាពរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើបានសរុបចំនួន ៤៥កន្លែង និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូចបានចំនួន៣០កន្លែង។

ការប្រមូលចំណូលក្នុងឆ្នាំ២០២៥ បានសរុបចំនួន ១ ០៤៦ ៨៣៤ ១៥០រៀល ក្នុងនោះប្រាក់ចំណូលពីផ្នែកផលិតកម្ម និងបសុព្យាបាលចំនួន ៧១៧ ១៣២ ៧០០រៀល ពីផ្នែកជលផលចំនួន ១៨៩ ៦០០ ០០០រៀល ( ប្រាក់ឈ្នួលដាយត្រី)បង់ចូលអង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ និង៤៧ ២០០ ០០០រៀល ពីការចេញលិខិតអនុញ្ញាត បង់ចូលថ្នាក់ជាតិតាមរយៈរដ្ឋបាលជលផល និងពីផ្នែកព្រៃឈើចំនួន ៩២ ៩០១ ៤៥០រៀល ពីការចេញលិខិតអនុញ្ញាត បង់ចូលថ្នាក់ជាតិតាមរយៈរដ្ឋបាលព្រៃឈើ។

## ២. **ស្ថានភាពមន្ត្រី** ( ឧបសម្ព័ន្ធ១ )

មន្ត្រីរាជការកំពុងបម្រើការងារក្នុងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ មានចំនួន១៥៥នាក់(ស្រី៣០នាក់) ក្នុងនោះមន្ត្រីក្របខ័ណ្ឌ"ក" ចំនួន៨២នាក់(ស្ត្រី១០នាក់) ក្របខ័ណ្ឌ"ខ" ចំនួន៤៤នាក់ (ស្ត្រី១៤នាក់) ក្របខ័ណ្ឌ"គ" ចំនួន២៩នាក់(ស្ត្រី៦នាក់) និងមន្ត្រីជាប់កិច្ចសន្យាសរុបចំនួន៨នាក់(ស្រី២នាក់)។

នៅក្នុងឆ្នាំ២០២៥នេះ មានមន្ត្រីបានចូលនិវត្តន៍ចំនួន២នាក់(ស្ត្រី១នាក់) មន្ត្រីបានផ្ទេរក្របខ័ណ្ឌទៅបម្រើការងារនៅអង្គភាពផ្សេង១នាក់ មន្ត្រីបានផ្លាស់ចូលមកពីអង្គភាពផ្សេង១នាក់ និងមន្ត្រីទទួលមរណភាព១នាក់ ។

មន្ត្រីរាជការមានកម្រិតជំនាញ ថ្នាក់បណ្ឌិត ២នាក់(ស្ត្រី០នាក់) ថ្នាក់អនុបណ្ឌិត ៣១នាក់(ស្ត្រី០៥នាក់) បរិញ្ញាបត្រ ៧១នាក់(ស្ត្រី០៧នាក់) បរិញ្ញាបត្ររង ៣៤នាក់(ស្ត្រី១៣នាក់) បឋម១៣នាក់(ស្ត្រី០៤នាក់) និងគ្មានសញ្ញាបត្រ ០៤នាក់(ស្ត្រី០១នាក់)។

មន្ត្រីនៅតាមអង្គភាព និងការិយាល័យជំនាញក្រោមឱវាទមន្ទីរ ៖

- ថ្នាក់ដឹកនាំមន្ទីរ សរុប ០៤នាក់ (ប្រធានមន្ទីរ ០១រូប និងអនុប្រធានមន្ទីរ ០៣រូប)
- អង្គភាព និងការិយាល័យជំនាញ សរុប ១៥១នាក់(ស្ត្រី៣០នាក់)

| | | | |
|---|---|---|---|
| •ខណ្ឌរដ្ឋបាលព្រៃឈើ | ៥១នាក់(ស្ត្រី១នាក់) | •ខណ្ឌរដ្ឋបាលជលផល | ២៨នាក់(ស្ត្រី៥នាក់) |
| •ការិយាល័យរដ្ឋបាល បុគ្គលិក | ០៤នាក់(ស្ត្រី១នាក់) | •ការិ.ផែនការ គណនេយ្យ | ០៦នាក់(ស្ត្រី៣នាក់) |
| •ការិ.ផលិតកម្ម និងបសុព្យាបាល | ៣០នាក់(ស្ត្រី៦នាក់) | •ការិ.ផ្សព្វផ្សាយកសិកម្ម | ០៤នាក់(ស្ត្រី២នាក់) |
| •ការិ.ក្សេត្រសាស្ត្រនិងផលិតភាពកសិកម្ម | ០៦នាក់(ស្ត្រី៣នាក់) | •ការិ.គ្រឿងយន្តកសិកម្ម | ០៥នាក់(ស្ត្រី៣នាក់) |
| •ការិ.អភិវឌ្ឍន៍សហគមន៍កសិកម្ម | ០៥នាក់(ស្ត្រី៣នាក់) | •ការិយាល័យនីតិកម្មកសិកម្ម | ០៦នាក់(ស្ត្រី៣នាក់) |
| •ការិយាល័យកសិឧស្សាហកម្ម | ០៣នាក់(ស្ត្រី០នាក់) | •ការិយាល័យកៅស៊ូ | ០៣នាក់(ស្ត្រី០នាក់)។ |

## ២. **សកម្មភាព និងលទ្ធផលការងារ**

### **ក. ការងារបង្កបង្កើនផល** ( ឧបសម្ព័ន្ធ២ )

**ក.១.ស្រូវរដូវប្រាំង ឆ្នាំ២០២៤-២០២៥** (ចាប់ផ្ដើមពីខែវិច្ឆិកា ឆ្នាំ២០២៤ និងបញ្ចប់ត្រឹមខែមេសា ឆ្នាំ២០២៥)

- ផែនការ ៖ ២៨០ហ.ត
- ផ្ទៃដីភ្ជួររាស់សរុប ៖ ៣៤០ហ.ត « ភ្ជួររាស់ដោយគ្រឿងយន្ត »
- ផ្ទៃដីដាំដុះសរុប ៖ ៣៤០ហ.ត =១២១,៤៣%នៃផែនការ(ស្រូវពង្រោះ)
- ការប្រមូលផល ៖ ផ្ទៃដីប្រមូលផល : ៣៤០ហ.ត
  បរិមាណផល : ១ ២១៧តោន
  ទិន្នផល : ៣,៥៨តោន/ហ.ត។

**ក.២.ដំណាំរដូវប្រាំង ឆ្នាំ២០២៤-២០២៥** (ចាប់ផ្ដើមពីខែវិច្ឆិកា ឆ្នាំ២០២៤ និងបញ្ចប់ត្រឹមខែមេសា ឆ្នាំ២០២៥)

- ដំណាំសាកវប្បកម្ម ៖ អនុវត្តបានសរុប: ១១០ហ.ត = ៩១,៦៦% នៃផែនការ ១២០ហ.ត
  - ផ្ទៃដីប្រមូលផល : ១១០ហ.ត
  - បរិមាណផល : ៩០៨តោន
  - ទិន្នផល : ៨,២៥តោន/ហ.ត។

- ដំណាំឧស្សាហកម្ម ៖ អនុវត្តបានសរុប: ៣០ហ.ត = ១០០% នៃផែនការ ៣០ហ.ត
  - ផ្ទៃដីប្រមូលផល : ៣០ហ.ត
  - បរិមាណផល : ៣៣០,៥០តោន
  - ទិន្នផល : ១១តោន/ហ.ត។

**ក.៣.ស្រូវរដូវវស្សា ឆ្នាំ២០២៥** (ចាប់ផ្តើមពីខែឧសភា និងបញ្ចប់ប្រមូលផលខែធ្នូ ឆ្នាំ២០២៥)

- ផែនការ ៖ ៤ ២០០ហ.ត
- ផ្ទៃដីភ្ជួររាស់សរុប ៖ ៤ ៣២០ហ.ត « ភ្ជួររាស់ដោយគ្រឿងយន្ត »
- ផ្ទៃដីដាំដុះសរុប ៖ ៤ ៣២០ហ.ត =១០២,៨៥%នៃផែនការ
  - សន្ទូង ១៤៥ហ.ត
  - ពង្រោះ ៤ ១៧៥ហ.ត
- ការប្រមូលផល ៖ ផ្ទៃដីប្រមូលផល : ៤៣២០ហ.ត
  - បរិមាណផល : ១២៦៦០តោន
  - ទិន្នផល : ២,៩៣តោន/ហ.ត។

**ក.៤.ដំណាំរដូវវស្សា ឆ្នាំ២០២៥** (ចាប់ផ្តើមពីខែឧសភា និងបញ្ចប់ចុងខែតុលា ឆ្នាំ២០២៥)

- ដំណាំសាកវប្បកម្ម ៖ អនុវត្តបានសរុប: ១១៥ហ.ត = ៩៥,៨៣% នៃផែនការ ១២០ហ.ត
  - ផ្ទៃដីប្រមូលផល : ១១៥ហ.ត
  - បរិមាណផល : ៨៥៦តោន
  - ទិន្នផល : ៧,៤៤តោន/ហ.ត។
- ដំណាំឧស្សាហកម្ម ៖ អនុវត្តបានសរុប: ៤០ហ.ត = ១០០% នៃផែនការ ៤០ហ.ត
  - ផ្ទៃដីប្រមូលផល : ៤០ហ.ត
  - បរិមាណផល : ៣០៥តោន
  - ទិន្នផល : ៧,៦២តោន/ហ.ត។

**ក.៥.ផលប៉ះពាល់ដោយសារគ្រោះធម្មជាតិ និងការស្តារឡើងវិញ**

- នៅក្នុងខែមករា មានការរាំងស្ងួតបានបង្កផលប៉ះពាល់ដល់ដំណាំស្រូវរដូវប្រាំងសរុបចំនួន២១,៥០ហ.ត នៅសង្កាត់បឹងធំ ខណ្ឌកំបូល(ភូមិក្អែក ៨ហ.ត ភូមិដូនកុក ៣,៥ហ.ត និងភូមិខ្ទៅ ១០ហ.ត) តែមិនមានការខូចខាតទេ ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ បានសហការជាមួយមន្ទីរធនធានទឹក និងអាជ្ញាធរភូមិ-សង្កាត់នៅមូលដ្ឋានជួយអន្តរាគមន៍បូមទឹកជួយសង្គ្រោះទាន់ពេលវេលា។
- នៅដើមខែសីហា មានការរាំងស្ងួត ដែលបណ្តាលមានការប៉ះពាល់ផ្ទៃដីស្រូវសន្ទូង និងពង្រោះសរុបចំនួន ២៩៤ហ.ត នៅក្នុងសង្កាត់ប្រទះឡាង ខណ្ឌកំបូល រាជធានីភ្នំពេញ តែមិនមានការខូចខាតទេ ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ សហការជាមួយមន្ទីរធនធានទឹករាជធានីភ្នំពេញ និងអាជ្ញាធរភូមិ-សង្កាត់នៅមូលដ្ឋានអន្តរាគមន៍បូមទឹកសង្គ្រោះទាន់ពេលវេលា។

**ក.៦.ស្រូវរដូវប្រាំង ឆ្នាំ២០២៥-២០២៦** (ចាប់ផ្តើមពីខែវិច្ឆិកា,លទ្ធផលគិតត្រឹមសប្តាហ៍ទី២ខែធ្នូ ឆ្នាំ២០២៥)

- ផែនការ ៖ ៣១០ហ.ត (កើន ៣០ហត ធៀបផែនការឆ្នាំ២០២៤-២០២៥)
- ផ្ទៃដីភ្ជួររាស់សរុប ៖ ២៩៤ហ.ត « ភ្ជួររាស់ដោយគ្រឿងយន្ត »
- ផ្ទៃដីដាំដុះសរុប ៖ ២៩៤ហ.ត =៩៤,៨៣%នៃផែនការ(ស្រូវពង្រោះ)

នៅដើមខែវិច្ឆិកា មានជំនន់ទឹកភ្លៀងបណ្តាលឱ្យប៉ះពាល់ដល់ផ្ទៃដីស្រូវរដូវប្រាំង នៅក្នុងសង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញសរុបចំនួន៨ហ.ត ក្នុងនោះផ្ទៃដីស្រូវចំនួន៦,៥ហ.ត បានលូតលាស់ល្អឡើងវិញ ចំណែកឯផ្ទៃដីស្រូវ១,៥ហ.ត ទទួលរងការខូចខាតនិងបានព្រោះស្តារដាំឡើងវិញរួចរាល់។

**ក.៧.ដំណាំរដូវប្រាំង ឆ្នាំ២០២៥-២០២៦** (ចាប់ផ្តើមពីខែវិច្ឆិកា, លទ្ធផលគិតត្រឹមសប្តាហ៍ទី២ខែធ្នូ ឆ្នាំ២០២៥)

- ដំណាំសាកវប្បកម្ម ៖ ផែនការ១១០ហ.ត អនុវត្តបាន: ៥២ហ.ត = ៤៧,២៧% នៃផែនការ
- ដំណាំឧស្សាហកម្ម ៖ផែនការ៣០ហ.ត អនុវត្តបាន: ១៧ហ.ត = ៥៦,៦៦% នៃផែនការ

## ក.៨.ការគ្រប់គ្រងគ្រឿងយន្តកសិកម្ម

**ការភ្ជួររាស់**

- ភ្ជួររាស់ស្រូវប្រាំងឆ្នាំ២០២៤-២០២៥ ចំនួន ៣៤០ ហ.ត ( ប្រើប្រាស់គ្រឿងយន្ត ១០០% )
- ភ្ជួររាស់ស្រូវវស្សាឆ្នាំ២០២៥ ចំនួន ៤ ៣២០ ហ.ត ( ប្រើប្រាស់គ្រឿងយន្ត ១០០% )

**ការស្រង់ស្ថិតិ និងធ្វើបច្ចុប្បន្នភាពគ្រឿងយន្ត-ឧបករណ៍កសិកម្ម**

- សិប្បកម្មកែច្នៃ-ដំឡើងម៉ាស៊ីននិងឧបករណ៍កសិកម្ម ១កន្លែង , ទីតាំងលក់ម៉ាស៊ីន-ឧបករណ៍កសិកម្ម ២០កន្លែង , ទីតាំងលក់ដ្រូនកសិកម្ម ៦កន្លែង (មានដ្រូនកសិកម្មចំនួន២៦គ្រឿង)
- ត្រាក់ទ័រ ២២គ្រឿង គោយន្ត ៣០២គ្រឿង ម៉ាស៊ីនបូមទឹក ១ ៣០២គ្រឿង ម៉ាស៊ីនបាញ់ថ្នាំ ១៩៧គ្រឿង
- ម៉ាស៊ីនច្រូតស្រូវស្វ័យប្រវត្តិ ១៧ គ្រឿង ម៉ាស៊ីនកិនស្រូវ ២៣គ្រឿង ម៉ាស៊ីនសម្ងួត ០១គ្រឿង
- ឧបករណ៍បំពាក់ត្រាក់ទ័រ : នង្គ័ល ២២គ្រឿង រនាស់ ២២គ្រឿង អង្កប់វាយដី ២២គ្រឿង
- ឧបករណ៍បំពាក់គោយន្ត : នង្គ័ល ៣០២គ្រឿង រនាស់ ៣០២គ្រឿង និងកៀរពង្រាបដី១០គ្រឿង។

## ក.៩.ការអភិវឌ្ឍន៍សហគមន៍កសិកម្ម

- ក្រោមកិច្ចសហការ និងសម្របសម្រួលពីមន្ត្រីជំនាញ សហគមន៍កសិកម្មចំនួន៦សហគមន៍ នៅតំបន់ជាយរាជធានីភ្នំពេញបាននិងកំពុងពង្រឹង និងអភិវឌ្ឍន៍ការងារគ្រប់គ្រងសហគមន៍នៅក្នុងមូលដ្ឋានរបស់ខ្លួនដោយមានសមាជិកសរុបចំនួន ៣៣៦នាក់(ស្ត្រី២២១នាក់) មានភាគហ៊ុន ១ ៣៣៨ហ៊ុន ប្រាក់ភាគហ៊ុនសរុបចំនួន ១១១ ១០០ ០០០រៀល និងប្រាក់ទុនសហគមន៍សរុបចំនួន ១៨៤ ២៥៣ ១០០រៀល។

## ក.១០.ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម

- មានទីតាំងលក់ដុំ លក់រាយថ្នាំកសិកម្ម ជីកសិកម្ម ០៩កន្លែង
- មានទីតាំងលក់ដុំ លក់រាយជីកសិកម្ម ០៨កន្លែង
- បានចុះធ្វើបច្ចុប្បន្នភាពទីតាំងលក់ដុំ លក់រាយថ្នាំកសិកម្ម ជីកសិកម្ម ចំនួន ១៤លើក លើ ១០ទីតាំង
- បានចុះផ្សព្វផ្សាយដល់អាជីវករ ពីនីតិវិធីនៃការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មដែលធ្វើពាណិជ្ជកម្ម ណែនាំពីវិធីសាស្ត្រនៃការប្រើប្រាស់ថ្នាំកសិកម្ម និងការគ្រប់គ្រងកាកសំណល់ថ្នាំកសិកម្ម ។

## ក.១១.ការចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយ ណែនាំបច្ចេកទេស និងកិច្ចប្រជុំផ្សេងៗ

- ចូលរួមប្រជុំស្តីពីការចុះពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធអ្នកបង្កាត់ពូជដំណាំ ជាមួយក្រុមការងារនាយកដ្ឋានគ្រប់គ្រងពូជដំណាំ
- ចុះផ្សព្វផ្សាយ ណែនាំបច្ចេកទេសបង្កបង្កើនផលដំណាំស្រូវជូនប្រជាកសិករ និងចុះពិនិត្យផលប៉ះពាល់លើដំណាំ និងស្រូវវស្សា ដោយការរាំងស្ងួត នៅក្នុងសង្កាត់ប្រទះឡាង ខណ្ឌកំបូល
- ចុះណែនាំ និងចែករំលែកបទពិសោធន៍នៃការដាំដំណាំបន្លែនៅភូមិចំបក់មាស សង្កាត់បាក់ខែង នៅភូមិចុងកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ និងចុះណែនាំ និងចែករំលែកបទពិសោធន៍ការដាំដុះដំណាំស្រូវដល់កសិករនៅសង្កាត់ទៀន ខណ្ឌដង្កោ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការព្យាករសន្តិសុខស្បៀងសម្រាប់ដំណាំយុទ្ធសាស្ត្រ(ស្រូវ) នៃគម្រោងបង្កើតប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាស៊ាន និងការអភិវឌ្ឍធនធានមនុស្ស(ដំណាក់កាលទី៣)
- ចូលរួមសិក្ខាសាលាស្តីពីការពិនិត្យលើការប្រមូលទិន្នន័យផលិតកម្មកសិកម្ម
- សហការជាមួយរដ្ឋបាលរាជធានីភ្នំពេញ ចុះបើកវគ្គបណ្តុះបណ្តាលដល់សិស្សានុសិស្ស ស្តីពីការដាំដុះបន្លែសុវត្ថិភាពនៅអង្គការដើម្បីភាពញញឹមនៃកុមារ(PSE)
- ចូលរួមកិច្ចប្រជុំបឋមចាប់ផ្តើមគម្រោងស្រាវជ្រាវរវាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងកម្មវិធីស្បៀងអាហារពិភពលោក នៃអង្គការសហប្រជាជាតិ ស្តីពី "ការសិក្សាដើម្បីស្វែងមតិក្នុងចំណោមអាជីវករលក់អាហារតាមដងផ្លូវជុំវិញរោងចក្រ ដើម្បីបញ្ជ្រាបការប្រើប្រាស់អង្ករដែលមានបញ្ចូលមីក្រូសារជាតិ" និង "ការសិក្សាដើម្បីស្វែងមតិក្នុងចំណោមកម្មកររោងចក្រស្តីពីឥរិយាបថអតិថិជន ដោយផ្តោតលើចំណេះដឹងអាកប្បកិរិយា និងការអនុវត្តទាក់ទងនឹងអាហារូបត្ថម្ភ និងអង្ករ ដែលមានបញ្ចូលមីក្រូសារជាតិ" បែបគុណវិស័យ បរិមាណវិស័យ នៅរាជធានីភ្នំពេញ

- ចុះប្រមូលទិន្នន័យតួអង្គចម្បងៗក្នុងដំណាក់កាលប្រមូលទិញពីស្រែនៃខ្សែច្រវាក់តម្លៃស្រូវ អង្ករ នៅរាជធានី
- ចូលរួមកិច្ចប្រជុំស្តីពីកម្មវិធីបណ្តាញទំនាក់ទំនងភាពជាដៃគូរធុរកិច្ចរវាងសហភាពអឺរ៉ុប-កម្ពុជា«ការនាំចេញ និងនវានុវត្តន៍កសិកម្ម»
- ចុះស្រង់ស្ថិតិបរិមាណបន្លែនាំចូលក្នុងរាជធានីភ្នំពេញ ប្រភពនាំចូល និងបរិមាណចែកចាយទៅតាមបណ្តាខេត្ត នៅតាមទីផ្សារបោះដុំក្នុងរាជធានីភ្នំពេញ
- ចុះប្រមូលទិន្នន័យអាកាសយានគ្មានមនុស្សបើក(ដ្រូន) នៅតាមទីតាំងលក់គ្រឿងយន្ត និងឧបករណ៍កសិកម្ម និងណែនាំម្ចាស់អាជីវកម្មទៅធ្វើស្វ័យប្រកាសជាមួយអាជ្ញាធរមូលដ្ឋាន
- ចូលរួមវគ្គបណ្តុះបណ្តាល " គ្រូបង្គោល(TOT) ស្តីពីខ្សែច្រវាក់តម្លៃដែលគិតគូរពីអាហារូបត្ថម្ភ "
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី"ការអនុវត្ត អនាម័យល្អ ការវិភាគគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យសំខាន់ៗ (GHP/HACCP)"
- ចូលរួមកម្មវិធីប្រឡងប្រជែងអ្នកកែច្នៃប្រហុកឆ្នើម ឆ្នាំ២០២៥
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការពង្រឹងគុណភាពជីកសិកម្ម និងថ្នាំកសិកម្ម នៅអគ្គនាយកដ្ឋានកសិកម្ម
- ចុះធ្វើបច្ចុប្បន្នភាព និងត្រួតពិនិត្យទីតាំងអាជីវកម្មថ្នាំកសិកម្ម និងជីកសិកម្មនៅក្នុងខណ្ឌពោធិ៍សែនជ័យ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌដូនពេញ ខណ្ឌបឹងកេងកង ខណ្ឌចំការមន ខណ្ឌកំបូល និងខណ្ឌសែនសុខ
- សម្របសម្រួលជាមួយគណៈកម្មការសហគមន៍ ជួយរៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំចំនួន៦សហគមន៍ ចូលរួមមហាសន្និបាតប្រចាំឆ្នាំចំនួន៣សហគមន៍ ចូលរួមកិច្ចប្រជុំស្តីពីការបិទបញ្ជីប្រចាំខែ និងផ្សព្វផ្សាយយុទ្ធសាស្ត្រទីផ្សារដល់គណៈកម្មការសហគមន៍កសិកម្ម
- ចូលរួមផ្សព្វផ្សាយស្តីពីការបោះឆ្នោតជ្រើសរើសបេក្ខភាពក្រុមប្រឹក្សាភិបាល និងគណៈកម្មការត្រួតពិនិត្យសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ចូលរួមសិក្ខាសាលា"ការពិនិត្យឡើងវិញនៃការអនុវត្តច្បាប់ស្តីពីសហគមន៍កសិកម្មដោយសហគមន៍កសិកម្ម"
- ចូលរួមសិក្ខាសាលាចាប់ផ្តើមគម្រោងពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលសម្រាប់ការអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព និងបរិយាបន្ននៅកម្ពុជា នៅរាជធានីភ្នំពេញ។

## ខ. **ការងារចិញ្ចឹមសត្វ** ( ឧបសម្ព័ន្ធ៣ )

### ខ.១. ស្ថិតិសត្វ

- គោ ៤ ០២១ ក្បាល (សាច់ ៣ ៦៧៧ក្បាល អូសទាញ ៣៤៤ក្បាល)
- ក្របី ១៤០ ក្បាល(សាច់ ៨០ក្បាល អូសទាញ ៦០ក្បាល)
- ជ្រូក ២ ០៤០ ក្បាល(បា ៥ក្បាល មេ ១៦៦ក្បាល កូន ៦៣៥ក្បាល សាច់ ១ ២៣៤ក្បាល)
- សេះ ៧ ក្បាល
- ពពែ ១៦៥ ក្បាល
- ចៀម ២០០ ក្បាល
- ទន្សាយ ១០០០ ក្បាល
- ឆ្កែ ៨០ ៣៥៥ ក្បាល
- ឆ្មា ១៨ ៩៤៦ ក្បាល
- មាន់ ១៨១ ២៣៨ ក្បាល (មាន់ពង ៦៩ ០០០ក្បាល មាន់សាច់ ១១២ ៧៣៨ក្បាល)
- ទា ៣៦ ៣៨៥ ក្បាល (ទាកាប ៣៥ ៥៧០ក្បាល និងទាកាប៉ា ៨១៥ក្បាល)
- ក្ងាន ២៣៥ ក្បាល

ការចិញ្ចឹមសត្វសរុបចំនួន **៣២៤ ៧៣២ក្បាល។**

### ខ.២. ស្ថានភាពសត្វឈឺ ការព្យាបាល និងសត្វស្លាប់ដោយជំងឺ

- ការព្យាបាលសត្វសរុប: **៣ ៥៧៩ក្បាល** «គោ ១៩០ក្បាល ជ្រូក ១៧៨ក្បាល ឆ្កែ ១៧០០ក្បាល ឆ្មា ៣៧៦ក្បាល មាន់ ១១៣៥ក្បាល»
- សត្វស្លាប់សរុប: **៥២៤ក្បាល** «ជ្រូក ១០ក្បាល ឆ្កែ ២៥ក្បាល មាន់ ៤៨៩ក្បាល»។

## ខ.៣.វិធានការការពារជំងឺឆ្លងសត្វ

បានចុះទប់ស្កាត់ និងអនុវត្តវិធានបសុពេទ្យ នៅទីតាំងចិញ្ចឹមមាន់ របស់អង្គការ Resource Development International នៅភូមិព្រែកធំ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលទទួលរងការឆ្លងជំងឺផ្តាសាយបក្សីក្នុងអនុក្រម H5N1។ នៅទីតាំងខាងលើ មានចិញ្ចឹមសត្វមាន់តូចធំសរុបចំនួន ៤៣៤ក្បាលក្នុងនោះ សត្វមាន់បានស្លាប់ចំនួន ១៥៣ក្បាល (ចាប់ពីថ្ងៃទី១៨ - ២៧ / ០១ / ២៥) និងនៅសល់សត្វមាន់នៅរស់ចំនួន២៨១ក្បាល។ វិធានការដែលបានអនុវត្ត ៖ ១-បានសម្លាប់និងដុតកំទេចចោលសត្វមាន់រស់ដែលនៅសល់ ២-ណែនាំដល់ម្ចាស់សត្វមាន់ពីបច្ចេកទេស និងវិធានការការពារ-ទប់ស្កាត់ជំងឺឆ្លងពីសត្វទៅសត្វ និងឆ្លងពីសត្វទៅមនុស្ស ៣-អនុវត្តវិធានជីវសុវត្ថិភាព បាញ់ថ្នាំសម្លាប់មេរោគក្នុងនិងជុំវិញទ្រុងសត្វ ៤-បន្តចុះតាមដាន ពិនិត្យ និងអនុវត្តវិធានជីវសុវត្ថិភាព បាញ់ថ្នាំសម្លាប់មេរោគនៅក្នុង និងជុំវិញតំបន់ផ្ទុះជំងឺ សំដៅទប់ស្កាត់ការឆ្លងរាលដាលជំងឺផ្តាសាយបក្សីពីតំបន់ខាងលើទៅកាន់តំបន់ផ្សេងៗទៀត។

ការចុះពិនិត្យសុខភាពសត្វ និងផលិតផលសត្វ ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វ និងការធ្វើជីវសុវត្ថិភាព បាញ់ថ្នាំសម្លាប់មេរោគត្រូវបានអនុវត្តជាក់ស្តែងនៅតាមកសិដ្ឋាន សត្តឃាតដ្ឋាន ទីតាំងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ នៅតាមទីផ្សារ ទីសាធារណៈ និងកន្លែងកែច្នៃផលិតផលសត្វ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

-ការចាក់វ៉ាក់សាំងសត្វគោ ក្របី ពពែ ជ្រូក ឆ្កែ ឆ្មា មាន់ សរុបចំនួន **៥៥ ៦៤៦ក្បាល** នៅក្នុងនោះ៖

- ○ ចាក់វ៉ាក់សាំងសត្វគោ សរុប: **១ ៣៦៣ក្បាល** « សារទឹក ១០៤០ក្បាល អុតក្តាម ២០៣ក្បាល ដុំពក ១២០ក្បាល »
- ○ ចាក់វ៉ាក់សាំងសត្វក្របី សរុប: **១៦០ក្បាល** «សារទឹក ៨០ក្បាល អុតក្តាម ៨០ក្បាល»
- ○ ចាក់វ៉ាក់សាំងសត្វពពែ សរុប: **៣៣៣ក្បាល**«សារទឹក ៣៣៣ក្បាល »
- ○ ចាក់វ៉ាក់សាំងសត្វជ្រូកសរុប : **១ ៣៦៧ក្បាល** «អុតក្តាម ១២៥ក្បាល ប៉េស្ត ២៨១ក្បាល អូហ្សេស្គី ៤១៥ក្បាល ជាតិដែក ៣២០ក្បាល រាគកូនជ្រូក ២២៦ក្បាល »
- ○ ចាក់វ៉ាក់សាំងសត្វ ឆ្កែ ឆ្មា សរុប: **៥០៣០៣ក្បាល** «សត្វឆ្កែ ៤៩៧៣៧ក្បាល ឆ្មា ៥៦៦ក្បាល»
- ○ ចាក់វ៉ាក់សាំងសត្វ មាន់ សរុប:**២១២០ក្បាល** «អាសន្នរោគ៦៩០ក្បាល ញូកាស ១៤៣០ក្បាល»

- ត្រៀមចុះចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វគោ ក្របី សម្រាប់ឆមាសទី២ ឆ្នាំ២០២៥ ពីថ្ងៃទី១៥ ដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ នៅតាមបណ្តាខណ្ឌចំនួន៧ នៃរាជធានីភ្នំពេញ
- ការគ្រៀវសត្វឆ្កែ ឆ្មា សរុបចំនួន **៤៥ក្បាល** « ឆ្កែ ១៨ក្បាល ឆ្មា ២៧ក្បាល»
- ធ្វើជីវសុវត្ថិភាពបាញ់ថ្នាំសម្លាប់មេរោគ សរុប : **១ ៨៧៨លើក**
  « ទីតាំងចិញ្ចឹមសត្វ ៣២០លើក សត្តឃាតដ្ឋាន ១៤០០លើក ទីផ្សារ ១៥២លើក ផ្លូវជាតិ ៦លើក»។

## ខ.៤. ការត្រួតពិនិត្យអនាម័យសាច់សត្វ នៅទីសត្តឃាតដ្ឋាន

- គោ **៣៤១៨៥ក្បាល** គិតជាទម្ងន់សាច់ស្អាត ៣៥៨៩៤២៥គ.ក្រ និងសាច់មិនស្អាត ៣៦០គ.ក្រ
- ជ្រូក **៣១៤៨៩០ក្បាល** គិតជាទម្ងន់សាច់ស្អាត ២៥១៩១២០០គ.ក្រ និងសាច់មិនស្អាត ៤២០គ.ក្រ
- មាន់ **១២១២០២០ក្បាល** គិតជាទម្ងន់សាច់ស្អាត ១៤៥៤៤២៤គ.ក្រ ។
- សាច់ និងផលិតផលសត្វទាំងអស់ត្រូវបានអនុវត្តតាមនីតិវិធីនៃការត្រួតពិនិត្យសត្វរស់មុនពេលពិឃាត ត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វក្រោយពេលពិឃាត និងអូសត្រាសម្គាល់ពីមន្ត្រីបសុពេទ្យនៅតាមសត្តឃាតដ្ឋាន មុនពេលបញ្ចេញទៅកន្លែងតាំងលក់នៅតាមទីផ្សារ សំដៅធានាបាននូវគុណភាព សុវត្ថិភាពសាច់ និងផលិតផលសត្វ ដើម្បីរួមចំណែករក្សាបាននូវសុខភាពសាធារណៈ និងសុវត្ថិភាពចំណីអាហារនៅក្នុងរាជធានីភ្នំពេញ។ សាច់មិនស្អាតចំនួន **៧៨០គ.ក្រ**(សាច់ហើម ជាំ ដោយការប៉ះទង្គិចក្នុងពេលដឹកជញ្ជូន) ត្រូវបានដុតបំផ្លាញចោលមិនអនុញ្ញាតឱ្យធ្វើចរាចរចូលទីផ្សារឡើយ។

## ខ.៥. ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វនាំចូលរាជធានីភ្នំពេញ

- បរិមាណជ្រូក ក្នុងស្រុក សរុប: **៣១៤៨៩០ក្បាល**
  - ក្រុមហ៊ុន «ស៊ីភី» : ៩៤៤៦៥ក្បាល
  - ក្រុមហ៊ុនម៉ុងឫទ្ធី : ៦២៩៧៨ក្បាល

- ក្រុមហ៊ុនបេតាហ្គ្រោ : ៣១៤៨៩ក្បាល
- លក្ខណៈគ្រួសារ : ១៥៧៤៧ក្បាល
- កសិដ្ឋានក្នុងស្រុក : ១១០២១១ក្បាល

- គោ : **៣៤ ១៨៥ក្បាល**
- មាន់ : **១ ២១២ ០២០ក្បាល**

**ខ.៦. ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វនាំចេញ ៖ គ្មាន**

**ខ.៧. ទីតាំងលក់ជ្រូកខ្វៃ កន្លែងខ្វៃជ្រូក លក់សាច់ត្រជាក់ ក្នុងរាជធានីភ្នំពេញ**

- ខណ្ឌ៧មករា ទីតាំងខ្វៃជ្រូក ០៣កន្លែង លក់ជ្រូកខ្វៃ ១១កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌបឹងកេងកង ទីតាំងខ្វៃជ្រូក០២កន្លែង
- ខណ្ឌទួលគោក ទីតាំងខ្វៃជ្រូក ០៤កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌច្បារអំពៅ ទីតាំងខ្វៃជ្រូក ០១កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌមានជ័យ ទីតាំងខ្វៃជ្រូក និងលក់ជ្រូកខ្វៃ ០៧កន្លែង
- ខណ្ឌជ្រោយចង្វារ ទីតាំងលក់សាច់ត្រជាក់ ០១កន្លែង
- ខណ្ឌឫស្សីកែវ ទីតាំងខ្វៃជ្រូក ០៦កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌព្រែកព្នៅ ទីតាំងលក់សាច់ត្រជាក់ ០១កន្លែង
- ខណ្ឌសែនសុខ ទីតាំងខ្វៃជ្រូក ០១កន្លែង លក់សាច់ត្រជាក់ ០១កន្លែង
- ខណ្ឌដង្កោ ទីតាំងខ្វៃជ្រូក ០១កន្លែង លក់សាច់ត្រជាក់ ០១កន្លែង
- ខណ្ឌពោធិ៍សែនជ័យ ទីតាំងខ្វៃជ្រូក ០៤កន្លែង
- ខណ្ឌកំបូល ទីតាំងខ្វៃជ្រូក០២កន្លែង។

**ខ.៨.ការងារបង្ក្រាបបទល្មើសចលនាដឹកជញ្ជូនសត្វ ផលិតផលសត្វ**

ក.បានចូលរួមសហការជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ធ្វើការឃាត់ចាប់បទល្មើស ចំនួន២ករណី និងដុតកម្ទេចចោលវត្ថុតាងបទល្មើសដែលបានឃាត់ចាប់នាពេលកន្លងមក ៣លើក ៖

- ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៥ ឃាត់ចាប់រថយន្ត១គ្រឿង ដឹកពងមាន់ចំនួន១៥០ដុំ ស្មើនឹង៤៥០០០គ្រាប់ ដោយមិនមានលិខិតអនុញ្ញាត នៅលើផ្លូវស៊ីជីនពីង ភូមិព្រះធាតុ សង្កាត់រលួស ខណ្ឌដង្កោ
- ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៥ ឃាត់ចាប់រថយន្ត១គ្រឿង ដឹកពងមាន់ចំនួន៨០ដុំ ស្មើនឹង២៤០០០គ្រាប់ ដោយមិនមានលិខិតអនុញ្ញាត នៅលើផ្លូវជាតិលេខ១ មុខវត្តចំប៉ា សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ
- ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥ ចូលរួមដុតកម្ទេចចោលសាច់មាន់ និងស្លាបមាន់បង្កកខូចគុណភាព ចំនួន ១៥០០គីឡូក្រាម
- ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥ ចូលរួមដុតកម្ទេចចោលសាច់ និងផលិតផលសត្វបង្កក (គូទមាន់ ឆ្អឹងជំនីជ្រូក សរសៃគោ ខ្លាញ់ជ្រូក ស្លាបមាន់ សាច់មាន់កិន សាច់គោ សាច់ជ្រូក) ខូចគុណភាពនិង ហួសសុពលភាព ចំនួន ២៦១៦០គីឡូក្រាម
- ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ចូលរួមដុតកម្ទេចចោល កោះមាន់ ខូចគុណភាព ចំនួន ៤ តោន ។

ខ. ក្រុមការងារបង្ក្រាបបទល្មើសចលនាដឹកជញ្ជូនសត្វ ផលិតផលសត្វនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ បានចុះស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសសន្និធិ និងដឹកជញ្ជូនសត្វ និងផលិតផលមាន ដើមកំណើតពីសត្វ បានចំនួន០៤ករណី និងដុតកម្ទេចចោលវត្ថុតាងបទល្មើសដែលបានឃាត់ចាប់ ១ករណី :

- ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៥ បានឃាត់ចាប់រថយន្ត១គ្រឿង ដឹកមាន់រស់៣៦៤០ក្បាល ស្មើ៥២០ស្រកា ដោយ មិនមានលិខិតអនុញ្ញាត នៅចំណុចក្បែររង្វង់មូលគល់ស្ពានព្រែកព្នៅ ខណ្ឌព្រែកព្នៅ។ ករណីនេះ ជនល្មើស បានសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ចំនួន ១៥ លានរៀល ចូលថវិកាជាតិ
- ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ បានចុះបង្ក្រាបសកម្មភាពល្មើសច្បាប់នៅទីតាំងប្រមូលផ្តុំ និងពិឃាតសត្វ ជ្រូកខុសច្បាប់ របស់ឈ្មោះ ស៊ុន គឹមសៀ នៅសង្កាត់បឹងទំពន់២ ខណ្ឌមានជ័យ :

+ ឃាត់ចាប់សត្វជ្រូកចំនួន១៧៦ក្បាល បញ្ជូនទៅស្ថានីយចត្តាឡីស័ក នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីយកសំណាកទៅពិសោធន៍ស្វែងរកមេរោគជំងឺឆ្លងសត្វ

+ ឃាត់ចាប់ជ្រូកបង្អកចំនួន៤ទូ (៦០ក្បាល) ប្រគល់ជូនអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និងបង្រ្កាបការក្លែងបន្លំ (ក.ប.ប.) នៃក្រសួងពាណិជ្ជកម្ម តាមបញ្ជារបស់តំណាងអយ្យការ ដើម្បីពិសោធន៍រកសារធាតុគីមីខុសច្បាប់

+បន្ទាប់ពីពិនិត្យសំណាកនៅមន្ទីរពិសោធន៍រួច បង្ហាញថាសត្វជ្រូកដែលបានឃាត់ចាប់មានវត្តមានមេរោគប៉េស្តអាហ្វ្រិក African Swine Fever (ASF)

+បានរៀបចំចងក្រងសំណុំរឿងនៃបទល្មើសបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ តាមនីតិវិធីនៃច្បាប់ រីឯវត្ថុតាងជ្រូកចំនួន១៧៦ក្បាល ដែលមានមេរោគប៉េស្តអាហ្វ្រិក African Swine Fever (ASF) បានយកទៅដុតកម្ទេចចោលតាមវិធានបសុពេទ្យ

- ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៥ ឃាត់ចាប់រថយន្ត១គ្រឿង ដឹកកូនជ្រូកកណ្ដុររស់ចំនួន ១០៥ក្បាល ដោយមិនមានលិខិតអនុញ្ញាត នៅលើផ្លូវ៦០ម៉ែត្រ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ ។ ករណីនេះ ជនល្មើសបានសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ចំនួន ១៥ លានរៀល ចូលថវិកាជាតិ
- ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ បានឃាត់ចាប់កូនជ្រូកកណ្ដុររស់ចំនួន ៨៧ក្បាល នាំចូលពីប្រទេសវៀតណាម ដោយគ្មានលិខិតអនុញ្ញាត នៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ។ ករណីនេះ ជនល្មើសបានសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ចំនួន ១០ លានរៀល ចូលថវិកាជាតិ
- ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ បានរៀបចំពិធីដុតកម្ទេចវត្ថុតាងល្មើសច្បាប់ជ្រូកមានមេរោគប៉េស្តអាហ្វ្រិក African Swine Fever (ASF) ចំនួន១៧៦ក្បាល ដែលបានចុះបង្រ្កាប និងឃាត់ចាប់ នៅទីតាំងអាជីវកម្មប្រមូលផ្ដុំ និងពិឃាតសត្វជ្រូក គ្មានលិខិតអនុញ្ញាត នៅសង្កាត់បឹងទំពន់២ ខណ្ឌមានជ័យ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ ។

### ខ.៩. ការចូលរួមសិក្ខាសាលា វគ្គបណ្ដុះបណ្ដាល ផ្សព្វផ្សាយ ណែនាំបច្ចេកទេស និងកិច្ចប្រជុំផ្សេងៗ

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងសេចក្ដីណែនាំអន្តរក្រសួងស្ដីពីបែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់ស្ដីពីការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធការងារសុខភាពសត្វ និងផលិតកម្មសត្វ នៅរដ្ឋបាលរាជធានី ខេត្ត
- ចូលរួមវគ្គបណ្ដុះបណ្ដាលថ្នាក់ក្រោមជាតិ ស្ដីពីការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព្រឹត្តិការណ៍ដោយប្រើប្រាស់ឧបករណ៍៧-១-៧ សម្រាប់ព្រឹត្តិការណ៍សុខភាពសាធារណៈដល់មន្ត្រីក្រុមឆ្លើយតបបន្ទាន់ និងចូលរួមវគ្គបណ្ដុះបណ្ដាលថ្នាក់តំបន់ស្ដីពីការត្រៀមខ្លួនសម្រាប់ការឆ្លើយតបការផ្ទុះឡើងនៃជំងឺឈាមខ្មៅ
- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី "QGIS Animal for Veterinary Officers Responsible for Animal Disease Surveillance and Outbreak Investigations and Response" និង "Prudent use of Antimicrobials in livestock production and Launching good practice training manuals"
- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការកែលម្អរចនាសម្ព័ន្ធនិងកន្លែងពិឃាតសត្វ និងសិក្ខាសាលាថ្នាក់ជាតិស្ដីពីការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ រយៈពេល៥ឆ្នាំ(២០២៥-២០៣០)
- រៀបចំពិធីផ្សព្វផ្សាយ ណែនាំអំពីនីតិវិធីច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធសកម្មភាពអាជីវកម្មសន្និធិលក់ចែកចាយសាច់និងផលិតផលសត្វ ដល់ប្រធានក្រុមហ៊ុន ឬ តំណាងក្រុមហ៊ុន ម្ចាស់ទីតាំងអាជីវកម្មសន្និធិលក់ចែកចាយសាច់និងផលិតផលសត្វ នៅរាជធានីភ្នំពេញ ។

## គ. ការងារនេសាទ (ឧបសម្ព័ន្ធ៤)

### គ.១.អាជីវកម្មនេសាទ

- ស្ថិតិផលនេសាទៈ ផលត្រីចាប់បានសរុបចំនួន **១៧៥៦តោន**
  - ឧបករណ៍ឧស្សាហកម្ម (ដាយត្រី) ១០៣០តោន
  - នេសាទគ្រួសារក្នុងដែននេសាទ ៦៦៧តោន
  - នេសាទគ្រួសារតាមវាលស្រែ ៥៩តោន

- ការធ្វើនេសាទឧស្សាហកម្ម(ដាយត្រី) និងការធ្វើនេសាទជាលក្ខណៈគ្រួសារក្នុងដែននេសាទប្រមូលផល បានកើនជាងឆ្នាំមុនបន្តិចបន្តួច។ ត្រីដែលនេសាទបានរួមមាន ប្រភេទត្រីធំមានបរិមាណតិចតួច ដូចជា ត្រីឆ្ដោក ច្រកែង ប្រា ពោ កែស និងត្រីល្អិតចំរុះ( ត្រីប្រហុក ) ដូចជា ត្រីរៀល ស្លឹកឫស្សី ត្រីខ្នងវែង។ល។ ចំពោះ ការនេសាទជាលក្ខណៈគ្រួសារតាមវាលស្រែមានសកម្មភាពកើនជាងឆ្នាំមុន ។
- សកម្មភាពអាជីវកម្មនេសាទ រួមមាន ដាយត្រីចំនួន ១៤ ក្នុងចំណោមដាយត្រីចំនួន២២ នេសាទដោយឧបករណ៍រួមមាន នាម ចៃវ៉ា និងនេសាទជាលក្ខណៈគ្រួសារ ដូចជា មង ថ្នង សំណាញ់ សន្ទូច ។ល។

## គ.២.ស្ថិតិវារីវប្បកម្ម

- ត្រីចិញ្ចឹម សរុបចំនួន **២១ ៥០០តោន**
  - ចិញ្ចឹមតាមស្រះ ១៩ ៨០០តោន
  - ចិញ្ចឹមតាមបៃ ១ ៧០០តោន
- កង្កែបចិញ្ចឹម សរុបចំនួន **៤,២០តោន**
  - មេពូជ ៦០០ក្បាល
  - កូនកង្កែប ១៥ ០០០ក្បាល
- ក្រពើចិញ្ចឹម សរុបចំនួន **២០០ក្បាល**
  - ក្រពើមេ ១៧០ក្បាល
  - ក្រពើបា ៣០ក្បាល

  ក្នុងឆ្នាំ២០២៥នេះ ក្រពើចំនួន ៤៨៥ក្បាល ត្រូវបានលក់ចេញ ក្នុងនោះមាន ក្រពើមេ ២០០ក្បាល ក្រពើបា ១៣០ក្បាល និងក្រពើជំទង់ ១៥៥ក្បាល។
- ប្រជាជនយកចិត្តទុកដាក់ពង្រីកមុខរបរចិញ្ចឹមជីវិតតាមរយៈការធ្វើវារីវប្បកម្ម ការប្រមូលផលមានការកើនឡើងប្រៀបធៀបឆ្នាំ២០២៤។ ប្រភេទត្រីដែលដាក់ចិញ្ចឹមរួមមានត្រីប្រា ទីឡាព្យ៉ា កាបស កាបសាមញ្ញ ឆ្ពិន ពោ កែ ប្រាខ្មៅ និងកង្កែប។

## គ.៣.ការកែច្នៃផលនេសាទ

- ការកែច្នៃផលនេសាទ សរុបចំនួន **២ ៩៩០តោន** «ត្រីងៀត ប្រហុក ផ្អក ម៉ាំ ត្រីឆ្អើរ ត្រីប្រឡាក់ ប្រហិត .......»
- ផលិតទឹកត្រីចំនួន **៤ ២១៧ ១៤១លីត្រ** ។
- ការចេញលិខិតអនុញ្ញាតឱ្យបង្កើតទីតាំងទិញ លក់សន្និធិ ឬកន្លែងកែច្នៃផល ផលិតផលជលផលសរុបក្នុងឆ្នាំ ចំនួន **១១៨ច្បាប់**។

## គ.៤.ការនាំចូលផលនេសាទ

ការនាំចូលផលនេសាទ សរុបចំនួន **៤៨ ៦៣៤តោន**
- ផលនេសាទទឹកសាប ចំនួន ៤២ ២០៧តោន
- ផលនេសាទសមុទ្រ ចំនួន ៦ ៤២៧តោន។

## គ.៥.ផលនេសាទនាំចូលពីបណ្ដាខេត្ត

ការនាំចូលផលនេសាទពីបណ្ដាខេត្ត សរុបចំនួន **២៤ ៦៧២តោន**
- ផលនេសាទទឹកសាប ចំនួន ១៥ ២៧៥ តោន
- ផលនេសាទសមុទ្រ ចំនួន ៩ ៣៩៧តោន។

## គ.៦.ការងារបង្ក្រាបបទល្មើសនេសាទ

- ក្នុងឆ្នាំ២០២៥ បានកសាងកំណត់ហេតុបទល្មើសបំផ្លាញចោលសរុបចំនួន **២៨ករណី**។ វត្ថុតាងបំផ្លាញចោលរួមមាន៖ លបកន្ទុយកណ្ដុរ ៤០គ្រឿង លូស្បៃមុង ៤មាត់ របាំងស្បៃមុង ១៤៥ម៉ែត្រ បង្គោល ៧២ដើម មែកសម្រាស់ ២៦៧ដើម អាំងវ៉ែទ័រ ១គ្រឿង អាគុយ ១ កន្ត្រកដងត្រីមានខ្សែភ្លើងចំនួន៤ កានប្រេងចំណុះ៣០លីត្រចំនួន១២ និងលែងកូនត្រីចម្រុះ ៣៦គីឡូក្រាម

## គ.៧. ការចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយ ណែនាំបច្ចេកទេស និងកិច្ចប្រជុំផ្សេងៗ

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបទបញ្ញត្តិសហភាពអឺរ៉ុប និងការអនុវត្តល្អក្នុងប្រព័ន្ធគ្រប់គ្រងម្ហូបអាហារ ការពិនិត្យប្រព័ន្ធត្រួតពិនិត្យផ្លូវការ និងលក្ខខណ្ឌតម្រូវសម្រាប់ការនាំចេញផល ផលិតផលជលផលទៅកាន់ទីផ្សារសហភាពអឺរ៉ុប និងលក្ខខណ្ឌតម្រូវនៃប្រព័ន្ធ ហាសិប(HACCP) សម្រាប់ផល ផលិតផលជលផល
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ប្រកាសចំនួនប្រាំ សម្រាប់គាំទ្រមាត្រា៩ នៃច្បាប់ថ្មីស្តីពីជលផល"
- ចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធស្ថិតិជលផលឌីជីថល (Online Fish Stat System)
- ចូលរួមសិក្ខាសាលាបិទបញ្ចប់គម្រោង CAPFish-Capture លទ្ធផលទី១នៃប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពម្ហូបអាហារក្នុងវិស័យជលផល។

## ឃ. ការងារព្រៃឈើ ( ឧបសម្ព័ន្ធ៥ )

### ឃ.១.ការបណ្តុះ ចែកចាយ និងដាំកូនឈើ៖

- បណ្តុះកូនឈើ សរុបចំនួន **៧ ០០០ដើម**
- ចែកចាយកូនឈើ សរុបចំនួន **៣ ៣៣៧ដើម**
- ដាំកូនឈើ សរុបចំនួន **៣៨៦ដើម។**

កូនឈើនៅសល់ក្នុងថ្នាលសរុបចំនួន ២៩ ៦៦៤ដើម ក្នុងនោះ កូនឈើរយៈពេលខ្លី ៨០០ដើម កូនឈើរយៈពេលវែង ២៧ ៥៦៥ដើម និងកូនឈើហូបផ្លែ ១៩៥០ដើម។

ថ្នាក់ដឹកនាំមន្ទីរ នាយខណ្ឌ និងមន្ត្រីក្រោមឱវាទខណ្ឌរដ្ឋបាលព្រៃឈើភ្នំពេញ បានចូលរួមពិធីរុក្ខទិវា ៩ កក្កដា ឆ្នាំ២០២៥ នៅភូមិកសិដ្ឋាន ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

ថ្នាក់ដឹកនាំមន្ទីរ នាយខណ្ឌ និងមន្ត្រីក្រោមឱវាទខណ្ឌរដ្ឋបាលព្រៃឈើភ្នំពេញ បានរៀបចំពិធីដាំដើមឈើ និងចែកកូនឈើ នៅវិទ្យាល័យ ជាស៊ីម សន្ធរម៉ុក ក្រោមប្រធានបទ "ដាំដើមឈើ ដាំក្តីសង្ឃឹម" ក្រោមអធិបតីភាពឯកឧត្តម **យ៉ិនទៀង ពុទ្ធិរិទ្ធ** អនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខណ្ឌទួលគោក តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមកត្តិនីតិកោសលបណ្ឌិត **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខណ្ឌទួលគោក ដោយបានដាំដើមឈើប្រភេទប្រណីតធ្នង់ចំនួន ៣០ដើម នៅក្នុងបរិវេណប្រារព្ធពិធី និងបានដាំដើមឈើចម្រុះប្រភេទចំនួន ៥៨៧ដើម ផ្សេងទៀត នៅក្រៅទីតាំងប្រារព្ធពិធីតាមសួនឧទ្យាន គ្រឹះស្ថានសិក្សា វត្តអារាម ទីតាំងសាធារណៈ ព្រមទាំងបានចែកកូនឈើក្រញូង បេង នាងនួន ធ្នង់ គគីរ ចំនួន៥០០ដើម ជូនតំណាងរដ្ឋបាលខណ្ឌ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ដើម្បីយកទៅដាំនៅតាមដងផ្លូវ ទីសាធារណៈ និងលំនៅដ្ឋានរៀងៗខ្លួន។

### ឃ.២.រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ

- បានចេញលិខិតអនុញ្ញាតបន្តសុពលភាពសរុប៖
  - រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ ចំនួន **៤៥កន្លែង។**
  - រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច **៣០កន្លែង។**
- មានរោងម៉ាស៊ីនអារឈើ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទមធ្យមចំនួន **៣កន្លែង** ។
- មានរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ(ច្រកចេញចូលតែមួយ) ចំនួន **២កន្លែង** គឺក្រុមហ៊ុន អៀង ប៊ុនថន និងក្រុមហ៊ុន កែវ ស៊ីម ។

### ឃ.៣.ការដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូល ចេញ

- ការដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានមាន ឈើអារចម្រុះប្រភេទសរុបចំនួន **៤ ៩៩៧ម៣០៦៦** កូនឈើចំនួន **៩៧៨ដើម** និងអុសចំនួន **៩៥៣ស្ទែរ។**

### ឃ.៤.ការបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ

- បានតាមដាន ស្រាវជ្រាវបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃក្នុងដែនសមត្ថកិច្ចបានចំនួន០១ករណី ស្តីពីការធ្វើសន្និធិឈើអារក្រៅលំដាប់ថ្នាក់ចំនួន **៥ម៣៦៨៣** ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ។

**ង. ការងារគណនេយ្យ ហិរញ្ញវត្ថុ** ( ឧបសម្ព័ន្ធ៦ )

- **ង.១.ចំណូល** : ចំណូលសរុបចំនួន **១ ០៤៦ ៨៣៤ ១៥០រៀល** ក្នុងនោះ ៖
  - ចំនួន ៧១៧ ១៣២ ៧០០រៀលជាកម្រៃសេវាពីសត្តឃាតដ្ឋានក្នុងផ្នែកផលិតកម្ម និងបសុព្យាបាល (បង់ចូលថវិការដ្ឋ តាមរយៈអង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ)។
  - ចំនួន ១៨៩ ៦០០ ០០០រៀល ជាកម្រៃសេវាពីវិស័យជលផល (ជាថ្លៃឈ្នួលដាយត្រី) (បង់ចូលថវិការដ្ឋ តាមរយៈអង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ)។
  - ចំនួន ៤៧ ២០០ ០០០រៀល ជាកម្រៃមកពីសេវាសាធារណៈចេញលិខិតអនុញ្ញាតរបស់ខណ្ឌរដ្ឋបាលជលផល(បង់ចូលថវិកាជាតិតាមរយៈរដ្ឋបាលជលផល)។
  - ចំនួន ៩២ ៩០១ ៤៥០រៀល ជាកម្រៃមកពីសេវាសាធារណៈចេញលិខិតអនុញ្ញាតរបស់ខណ្ឌរដ្ឋបាលព្រៃឈើ និងការបង់ពិន័យអន្តរការណ៍លើសំណុំរឿង(បង់ចូលថវិកាជាតិតាមរយៈរដ្ឋបាលព្រៃឈើ)។

- **ង.២.ចំណាយ** : ចំណាយសរុបចំនួន **៤ ០៥០ ៥០៦ ៤១៥រៀល** ក្នុងនោះ៖
  - ចំនួន ៣ ៣៩២ ៤៦១ ៦៧៥រៀល ជាបៀវត្សមន្ត្រីរាជការ (ជំពូក៦៤)
  - ចំនួន ៧៦ ៦៤០ ០០០រៀល ជាប្រាក់កម្រៃមន្ត្រីជាប់កិច្ចសន្យា (ជំពូក៦៤)
  - ចំនួន ៨ ១០០ ០០០រៀល ជាប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំប្រពៃណីជាតិ (ជំពូក៦៤)
  - ចំនួន ២០ ៣២៤ ៦៤០រៀល ជាប្រាក់ឧបត្ថម្ភមន្ត្រីចូលនិវត្តន៍ (ជំពូក៦៤)
  - ចំនួន ៨ ០៥០ ០០០រៀល ជាប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ (ជំពូក៦៤)
  - ចំនួន ៨ ៩៩០ ៥៤០រៀល ជាប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រី (ជំពូក៦៤)
  - ចំនួន ៣៥២ ០១៣ ២៦០រៀល ជាការទិញ (ជំពូក ៦០)
  - ចំនួន ១៦២ ៩២៩ ៤០០រៀល ជាសេវាកម្ម (ជំពូក ៦១)
  - ចំនួន ១៩ ៩៩៦ ៩០០រៀល ជាអត្ថប្រយោជន៍សង្គម (ជំពូក ៦២)
  - ចំនួន ១ ០០០ ០០០រៀល ជាចំណាយផ្សេងៗ (ជំពូក ៦៣)

**ង.៣.ការចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយ ណែនាំបច្ចេកទេស និងកិច្ចប្រជុំផ្សេងៗ**

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើការងាររៀបចំតារាងសូចនាករតាមទិសដៅយុទ្ធសាស្ត្រទាំង៧នៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨
- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេស ស្តីពីការប្រមូលធាតុចូលសម្រាប់រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ របស់រដ្ឋបាលរាជធានីភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីពិធីការនិងបដិសណ្ឋារកិច្ច សិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០២៤-២០២៨ និងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហគ្រិនភាពជាស្ត្រី
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូលលើតារាងទិន្នន័យ មន្ទីរ អង្គភាពថ្នាក់ក្រោមជាតិ
- ចូលរួមសិក្ខាសាលាលើកកម្ពស់ការយល់ដឹង និងចែករំលែកព័ត៌មានអំពីដំណើរការនៃការត្រៀមចាកចេញរបស់កម្ពុជាពីចំណាត់ថ្នាក់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច
- ចូលរួមកិច្ចប្រជុំពិនិត្យផ្ទៀងផ្ទាត់លើរបាយការណ៍វិភាគទិន្នន័យចុងក្រោយនៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ និងចូលរួមក្នុងពិធីប្រកាសផ្សព្វផ្សាយរបាយការណ៍លទ្ធផលអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤
- ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីចុះសម្ភាសន៍ និងកត់ត្រាទិន្នន័យអង្កេតកសិកម្មឆ្នាំ២០២៥ និងចូលរួមប្រតិបត្តិការចុះសម្ភាសន៍ និងកត់ត្រាទិន្នន័យអង្កេតកសិកម្មឆ្នាំ២០២៥ នៅតាមបណ្តាភូមិក្នុងរាជធានី
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការចងក្រងស្ថិតិកសិកម្មលម្អិតតាមតំបន់
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការវិភាគទិន្នន័យកម្រិតបឋម និងមធ្យមសម្រាប់អ្នកធ្វើផែនការ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការរៀបចំកម្រងសំណួរ នឹងប្រើប្រាស់កម្មវិធីKoBo

- ចូលរួមវគ្គបណ្តុះបណ្តាលរិក្រឹតការស្តីពីការវិភាគស្ថិតិសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រ និងគោលនយោបាយជាតិ
- ចូលរួមសិក្ខាសាលាស្តីពី ការឆ្លុះបញ្ចាំងវឌ្ឍនភាព នៃការអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា ។

## ឆ. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យ អង្គភាពក្រោមឱវាទ( ឧបសម្ព័ន្ធ៧ )

| ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យ និងអង្គភាពក្រោមឱវាទ | កិច្ចប្រជុំ សិក្ខាសាលា សន្និបាត.... | ពិធីផ្សេងៗ | សរុប |
|---|---|---|---|
| ថ្នាក់ដឹកនាំមន្ទីរ | ១៨០ | ២១ | ២០១ |
| ខណ្ឌរដ្ឋបាលព្រៃឈើ | ១៩ | ១៤ | ៣៣ |
| ខណ្ឌរដ្ឋបាលជលផល | ២៩ | ៥ | ៣៤ |
| ការិ.រដ្ឋបាល បុគ្គលិក | ២៩ | ៣ | ៣២ |
| ការិ.ផែនការ គណនេយ្យ | ៧២ | ៣ | ៧៥ |
| ការិ.ផលិតកម្ម និងបសុព្យាបាល | ២១ | ២ | ២៣ |
| ការិ.ក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម | ១៩ | ២ | ២១ |
| ការិ.គ្រឿងយន្តកសិកម្ម | ៣ | - | ៣ |
| ការិ.ផ្សព្វផ្សាយកសិកម្ម | ៥ | ១ | ៦ |
| ការិ.អភិវឌ្ឍន៍សហគមន៍កសិកម្ម | ៦ | ១ | ៧ |
| ការិ.កសិឧស្សាហកម្ម | ៨ | ១ | ៩ |
| ការិ.នីតិកម្មកសិកម្ម | ៤ | ១ | ៥ |
| ការិ.កៅស៊ូ | ២ | ១ | ៣ |

## ជ. បញ្ហាប្រឈម និងដំណោះស្រាយ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| **១. ការងារបង្កបង្កើនផល** | | |
| | ការយល់ដឹងរបស់ប្រជាកសិករនៅមានកម្រិត ក្នុងផលិតកម្មកសិកម្ម និងការបង្កើនទិន្នផលស្រូវ និងដំណាំ។ | ចាត់មន្ត្រីជំនាញចុះផ្សព្វផ្សាយណែនាំបច្ចេកទេសសាមញ្ញៗ ដែលកសិករអាចយកទៅអនុវត្តបាន ដើម្បីជួយកសិករពង្រឹងសមត្ថភាព បច្ចេកទេស សំដៅបង្កើនទិន្នផលស្រូវ និងដំណាំឲ្យទទួលបានផលខ្ពស់ មានដូចជា៖<br>១.ករណីដីស្រែប្រភេទដីអាស៊ីត(PHតិច)ត្រូវបាចកំបោរស ឬផេះ ដើម្បីបង្កើន(PH) ឲ្យបាន ៦,៥-៧,៥<br>២.ត្រូវភ្ជួរលុបចំបើង និងគល់ជញ្រាំងចូលក្នុងដី បន្ទាប់ពីប្រមូលផលស្រូវរួច ដើម្បីបង្កើនសារធាតុចិញ្ចឹម NPK<br>៣.ការរៀបចំដី ត្រូវពង្រាបដីឲ្យបានរាបស្មើ ងាយស្រួល ក្នុងការគ្រប់គ្រងទឹក និងសារធាតុចិញ្ចឹមបានស្មើគ្នា<br>៤.មុនសាប ស្ទូង និងព្រោះ ត្រូវប្រើប្រាស់ជីសរីរាង្គទ្រាប់បាត<br>៥.ប្រើប្រាស់គ្រាប់ពូជស្រូវសុទ្ធល្អ<br>៦.ចុះស្រែជាប្រចាំ ដើម្បីគ្រប់គ្រងទឹក សត្វល្អិត ជំងឺ និងគ្រប់គ្រងសារធាតុចិញ្ចឹម<br>៧.ការទុកដាក់គ្រាប់ពូជស្រូវ ត្រូវច្រូតកាត់ក្នុងសំណើម២១% -២៥% ហាលឲ្យស្ងួតល្អរហូតត្រឹមសំណើម១៣%-១៤%។ |
| **២. ការងារចិញ្ចឹមសត្វ** | | |
| | ដោយសារកំណើនប្រជាពលរដ្ឋមករស់នៅប្រកបរបរ ទទួលទាននៅរាជធានីភ្នំពេញកាន់តែច្រើនធ្វើឲ្យសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតឲ្យ | -ចុះពិនិត្យការអនុវត្តវិធានបសុពេទ្យ បទដ្ឋានអនាម័យ និងបច្ចេកទេសនៅតាមសត្តឃាតដ្ឋានដែលមានលិខិតអនុញ្ញាត |

## ឈ. ផែនការប្រចាំឆ្នាំ២០២៦

| ល.រ | សកម្មភាពជាអាទិភាព | ២០២៦ |
| --- | --- | --- |
| | **ក.ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម** | |
| ១ | ចុះផ្សព្វផ្សាយ និងជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំផ្សេងៗ។ | ✓ |
| ២ | ចុះផ្សព្វផ្សាយណែនាំបច្ចេកទេសសមស្របដល់កសិករដើម្បីបង្កើនទិន្នផលស្រូវនិងដំណាំផ្សេងៗ | ✓ |
| | សហការជាមួយការិយាល័យជំនាញ និងមន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ ដើម្បី | |
| ៣ | រៀបចំផែនការត្រៀមសម្រាប់អន្តរាគមន៍ក្នុងករណីមានគ្រោះធម្មជាតិកើតឡើង។ | ✓ |
| | **ខ.ការិយាល័យផលិតកម្ម និងបសុព្យាបាល** | |
| | បង្កើនការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលមានដើមកំណើតពីសត្វ។ | ✓ |
| ៤ | ជំរុញការងារចិញ្ចឹមសត្វ ជាលក្ខណៈគ្រួសារ និងពាក់កណ្តាលឧស្សាហកម្ម។ | ✓ |
| ៥ | បង្កើនការត្រួតពិនិត្យការស្តុក ការដឹកជញ្ជូនចលនាសត្វរស់ និងផលិតផលមានដើមកំណើតពី | |
| ៦ | សត្វ ចេញ ចូលរាជធានីភ្នំពេញ និងមានវិធានការទប់ស្កាត់ជំងឺឆ្លងសត្វ។ | ✓ |
| | កែលម្អរចនាសម្ព័ន្ធសត្តឃាតដ្ឋានឲ្យមានអនាម័យសមស្របតាមលក្ខណៈបច្ចេកទេស។ | ✓ |
| ៧ | ជំរុញម្ចាស់សត្តឃាតដ្ឋានដែលមិនទាន់បានបំពេញបែបបទលិខិតស្នាមស្នើសុំបង្កើត | |
| ៨ | សត្តឃាតដ្ឋានតាមខ្លឹមសារនៃអនុក្រឹត្យលេខ ១០៨ អនក្រ.បក ឲ្យបានទាន់ពេលវេលា។ | ✓ |
| ៩ | ត្រៀមទីទួលសុវត្ថិភាព និងថ្នាំព្យាបាលសត្វក្នុងករណីមានគ្រោះធម្មជាតិកើតឡើង។ | ✓ |
| ១០ | ត្រួតពិនិត្យទីតាំងសាច់ត្រជាក់នៅតាមបណ្តាខណ្ឌ។ | ✓ |
| | **គ.ខណ្ឌរដ្ឋបាលជលផល** | |
| ១១ | ចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ។ | ✓ |
| ១២ | តាមដាន និងត្រួតពិនិត្យការធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទ។ | ✓ |
| ១៣ | ជំរុញការធ្វើវារីវប្បកម្មឲ្យបានទូលំទូលាយ ពិសេសតំបន់ជាយរាជធានីភ្នំពេញ។ | ✓ |
| | **ឃ.ខណ្ឌរដ្ឋបាលព្រៃឈើ** | |
| ១៤ | ចុះពិនិត្យ ថែទាំ ដាំជួសដើមឈើដែលបានដាំរួចនៅតាមដងផ្លូវក្នុងរាជធានី។ | ✓ |
| ១៥ | ថែទាំ និងចែកចាយកូនឈើសម្រាប់ដាំក្នុងរាជធានីភ្នំពេញ។ | ✓ |
| ១៦ | ចុះផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានផ្សេងៗ។ | ✓ |
| ១៧ | ចុះត្រួតពិនិត្យ និងកាត់ស្តុកតាមរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និង រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ។ | ✓ |
| ១៨ | ចុះត្រួតពិនិត្យការដឹកជញ្ជូនផល អនុផលព្រៃឈើ ចូល ចេញ និងឆ្លងកាត់។ | ✓ |
| ១៩ | ចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ។ | ✓ |
| | **ង.ការិយាល័យផ្សេងៗ** | |
| ២០ | ជំរុញការអនុវត្ត និងណែនាំបច្ចេកទេសបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ។ | ✓ |
| ២១ | បន្តចុះពិនិត្យលើការប្រើប្រាស់ឧបករណ៍កសិកម្មក្នុងការបង្កបង្កើនផលស្រូវ។ | ✓ |
| ២២ | ចុះធ្វើបច្ចុប្បន្នភាពទីតាំងលក់គ្រឿងយន្តកសិកម្មក្នុងរាជធានីភ្នំពេញ។ | ✓ |
| ២៣ | បន្តចូលរួមសម្របសម្រួលពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍កសិកម្ម។ | ✓ |
| ២៤ | ចុះផ្សព្វផ្សាយច្បាប់សហគមន៍កសិកម្ម និងពង្រឹងការងារគ្រប់គ្រងសហគមន៍កសិកម្ម។ | ✓ |
| ២៥ | ចុះធ្វើបច្ចុប្បន្នភាពទីតាំងកែច្នៃផលិតផលកសិកម្ម។ | ✓ |
| ២៦ | ចុះផ្សព្វផ្សាយបច្ចេកទេសកែច្នៃផលិតផលកសិកម្មក្រោយពេលប្រមូលផលដល់កសិករ។ | ✓ |
| ២៧ | ចុះស្ទង់តម្លៃផលិតផលកសិ-ឧស្សាហកម្មនៅតាមផ្សារធំៗក្នុងរាជធានី។ | ✓ |
| ២៨ | ចុះធ្វើបច្ចុប្បន្នភាព និងត្រួតពិនិត្យទីតាំងលក់ជី និងថ្នាំកសិកម្មតាមខណ្ឌនានាក្នុងរាជធានី។ | ✓ |
| ២៩ | បន្តទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងស្ថាប័នពាក់ព័ន្ធក្នុងការបំពេញការងារ។ | ✓ |
| ៣០ | ប្រមូលទិន្នន័យកៅស៊ូ និងតម្លៃកៅស៊ូ។ | ✓ |

ថ្ងៃ អង្គារ ១១កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២៥

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ**

**ញៀម តារារិទ្ធ**